USAID
ជំនួយពីពលរដ្ឋអាមេរិក

psi Cambodia

# ផ្សារភ្ជាប់ចំណេះដឹងផ្នែកយេនឌ័រ ទៅកម្មវិធីលើកកម្ពស់សុខភាព

*លោកស្រី រ៉ាយ រ៉ានី ស្តាប់យ៉ាងយកចិត្តទុកដាក់ នៅពេលដែលអ្នកសម្របសម្រួល ដឹកនាំការពិភាក្សាអំពីតួនាទីនៃយេនឌ័រ ដែលវគ្គបណ្តុះបណ្តាលនេះធ្វើឡើងកាលពីថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២១ ក្រោមប្រធានបទ "ការដាក់បញ្ចូលយេនឌ័រក្នុងការបង្កើតគម្រោងសុខភាព" ។ បន្ទាប់ពីមានការពិភាក្សារួច សិក្ខាកាមក៏បានចូលរួមធ្វើលំហាត់ផងដែរ ទាក់ទងនឹងការគូររូបដើមឈើដែលបង្ហាញអំពីការសម្រេចចិត្តរបស់បុរស និងស្ត្រីទាក់ទងនឹងកិច្ចការទូទៅនៅក្នុងផ្ទះ។*



លោកស្រី រ៉ានី គឺជាបុគ្គលយ៉ាងសំខាន់ម្នាក់នៅក្នុងមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព (NCHP) នៃក្រសួងសុខាភិបាល។ លោកស្រីបានធ្វើការនៅមជ្ឈមណ្ឌលជាង១៨ឆ្នាំមកហើយ ដោយលោកស្រីទទួលបន្ទុកផ្នែកថ្នាំជក់ ឬសុខភាព និងគ្រឿងស្រវឹង។ លោកស្រីដឹកនាំក្រុមការងារទៅលើកិច្ចការជាច្រើនដូចជា ការងារអប់រំ និងកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់ និងគ្រឿងស្រវឹង ជំរុញការអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ការត្រួតពិនិត្យលើការអនុវត្តវិធានការការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់ វិធានការហាមឃាត់ការផ្សព្វផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីដោយឧស្សាហកម្មថ្នាំជក់ វិធានការហាមជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ ឬកន្លែងសាធារណៈ និងគ្រឿងស្រវឹងជាដើម។ ក្នុងនាមជាបុគ្គលិក NCHP លោកស្រី មានឱកាសធ្វើការជាមួយបុគ្គលិកដែលគោរពបុរស និងស្ត្រីស្មើគ្នា។ លោកស្រីបានប្រាប់ឲ្យដឹងថា "នៅក្នុងកន្លែងធ្វើការរបស់ខ្ញុំ ស្ត្រី និងបុរសទទួលបានសិទ្ធិ និងការការពារស្មើគ្នា។"

វគ្គបណ្តុះបណ្តាលនេះ បានផ្តល់ជូនលោកស្រី និងសហការីរបស់លោកស្រី១៧នាក់ទៀត នូវឱកាសក្នុងការយល់ដឹងកាន់តែច្រើនទាក់ទងនឹងប្រធានបទផ្សេងៗអំពីយេនឌ័រ រួមមានវិធីសាស្ត្រសម្រាប់សមភាពយេនឌ័រ ការវិភាគយេនឌ័រ និងការដាក់បញ្ចូលយេនឌ័រទៅក្នុងផែនការរបស់គម្រោងសុខភាពជាដើម ដែលប្រធានបទទាំងអស់នេះ បានជួយដល់លោកស្រីនូវ**ការគិតជាយុទ្ធសាស្ត្រ ដើម្បីពង្រឹងកម្មវិធីសុខភាព និងធ្វើឲ្យសកម្មភាពគម្រោងបានទៅដល់ប្រជាជនគោលដៅ។**

**ការយល់ដឹងនូវបទដ្ឋានយេនឌ័រ និងសង្គមដែលនាំឲ្យមានឥទ្ធិពលដល់ជីវិត និងឱកាសរបស់ក្រុម យេនឌ័រនិមួយៗពិតជាមានសារៈសំខាន់ណាស់។** ដូច្នេះហើយ លោកស្រីមានបំណងប្រើប្រាស់ចំណេះដឹងដែលលោកស្រីទទួលបាន ដើម្បីជួយដល់អ្នកដទៃ ជាពិសេសប្រជាជននៅក្នុងសហគមន៍ ឲ្យទទួលបានព័ត៌មានស្តីពី សុខភាព ដោយមិនគិតថាគេជាយេនឌ័រណាទេ។

ការងាររបស់លោកស្រីតម្រូវឲ្យលោកស្រីគិតបែបយុទ្ធសាស្ត្រ និងចូលរួមដល់ការបង្កើតគោលនយោបាយ និងផែនការជាតិ រួមទាំងរៀបចំយុទ្ធនាការផ្សេងៗ រួមមានការធ្វើវីដេអូផ្សព្វផ្សាយ និងបង្កើតសម្ភារអប់រំ អំពីផលប៉ះពាល់នៃការប្រើប្រាស់ផលិតផលថ្នាំជក់ និងគ្រឿងស្រវឹង។ ការគិតគូរអំពីយេនឌ័រទៅក្នុងយុទ្ធនាការទាំងនេះ ពិតជាមានសារៈសំខាន់ក្នុងការធ្វើឲ្យយុទ្ធនាការសុខភាពទទួលបានជោគជ័យ។ លោកស្រីបាននិយាយថា "ខ្ញុំបានបញ្ចូលការគិតគូរអំពីយេនឌ័រទៅក្នុងកិច្ចការរបស់ខ្ញុំ។ ខ្ញុំមានមោទនភាពនឹងការងារខ្ញុំណាស់ ព្រោះខ្ញុំចូលចិត្តធ្វើការលើការអប់រំ និងលើកកម្ពស់សុខភាព។ ឧទាហរណ៍ សម្រាប់យុទ្ធនាការស្តីពីថ្នាំជក់របស់យើង យើងមានការចូលរួមពីសំណាក់ក្រុមគោលដៅទាំងបុរសនិងស្ត្រី" ។

បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាលអំពីយេនឌ័រនេះ ដែលរៀបចំឡើងដោយគម្រោង "លើកកម្ពស់ឥរិយាបថប្រកបដោយសុខុមាលភាព (PHB)" ដែលជាគម្រោងដែលទទួលការឧបត្ថម្ភថវិកាដោយ USAID លោកស្រីរ៉ានី បាននិយាយបន្ថែមទៀតថា វគ្គបណ្តុះបណ្តាលនេះបានជួយដល់លោកស្រី និងក្រុមការងារបានរៀនសូត្រ និងស្វែងយល់កាន់តែច្បាស់អំពីបញ្ហាយេនឌ័រ ហើយប្រធានបទខ្លះដែលបានពិភាក្សានៅក្នុងវគ្គបណ្តុះបណ្តាលនេះ អាចយកទៅគិតគូរទាំងនៅក្នុងសង្គម និងគ្រួសារ។ **វគ្គបណ្តុះបណ្តាលនេះ គឺជាកិច្ចខិតខំប្រឹងប្រែងរបស់គម្រោង PHB ក្នុងការរួមបញ្ចូលយេនឌ័រទៅក្នុងកម្មវិធីសុខភាពរបស់ខ្លួន ដោយបង្កើនសមត្ថភាព និងលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ** ដល់អ្នកដឹកនាំផ្នែកសុខភាព បុគ្គលិកគម្រោង ព្រមទាំងដៃគូអនុវត្តគម្រោងផងដែរ។ គម្រោង PHB ធ្វើការជាមួយអ្នកដឹកនាំផ្នែកសុខភាពដូចជាលោកស្រីរ៉ានី ដើម្បីបង្កើនចំណេះដឹងផ្នែកយេនឌ័រ ភាពជាអ្នកដឹកនាំ និងការស្វែងរកការគាំទ្រ ព្រមទាំងលើកទឹកចិត្តពួកគាត់ក្នុងការធ្វើជាអ្នកដឹកនាំគំរូ និងដើម្បីបង្កើតលទ្ធផលការងារជំរិជ្ជមាននៅក្នុងស្ថាប័នរបស់ពួកគាត់។

"មនុស្សទាំងអស់កើតមកគឺមានសេរីភាពនិងមានសិទ្ធិព្រមទាំងកិត្តិយសស្មើគ្នា។" លោកស្រីបានបន្ថែមទៀតថា "ចំណេះដឹងពីវគ្គបណ្តុះបណ្តាលនេះ ដែលខ្ញុំកំពុងប្រើ ឬនឹងប្រើនៅក្នុងការងាររបស់ខ្ញុំ និងជួយឲ្យក្រុមការងាររបស់ខ្ញុំសម្រេចបាននូវគោលដៅសមភាពយេនឌ័ររបស់យើង"។

https://www.psi.org.kh/km/phb/

*ខ្លឹមសារនៃអត្ថបទនេះគឺជាការទទួលខុសត្រូវរបស់អ្នកសរសេរ ហើយមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកទេ។*